**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
លេខ:០០៧/...២៥..... អអរ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ដឹកនាំកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការនាយករដ្ឋមន្ត្រី (វិមានសន្តិភាព) នាព្រឹកថ្ងៃសុក្រ ៧កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៥ ដោយបានពិភាក្សាឆ្លង និងអនុម័តរបៀបវារៈសំខាន់ៗ ដូចខាងក្រោម៖

## ១. សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា

សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភាត្រូវបានរៀបចំឡើងបន្តពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ទៅតាមការចង្អុលបង្ហាញនិងមគ្គុទ្ទេសក៍របស់យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ហើយមានឋានានុក្រមទី៣ នៅក្នុងឯកសារក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍ជាតិ បន្ទាប់ពីកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១។ សេចក្តីព្រាង ផ.យ.អ.ជ. នេះ ជាផែនការចង្អុលបង្ហាញក្នុងរយៈពេលមធ្យមក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចទីផ្សារ និងជាឧបករណ៍គោលនយោបាយចម្បងក្នុងការអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្ររួមរបស់រាជរដ្ឋាភិបាល សម្រាប់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងបានគិតគូរពីការប្រែក្លាយការតម្រង់ទិសគោលនយោបាយយុទ្ធសាស្ត្រធំៗ របស់យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ឱ្យទៅជាសកម្មភាពដែលអាចអនុវត្តបាន និងមានចរិតជាការកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។

សេចក្តីព្រាងនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងសំខាន់ចំនួន ៣ គឺ ទី១. ដើម្បីវាយតម្លៃអំពីលទ្ធផលរួមនិងបញ្ហាប្រឈមចម្បងៗ ដែលបានកើតមានឡើងនៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ទី២. ដើម្បីដាក់ចេញនូវវិធានការ សកម្មភាព និងកម្មវិធីអាទិភាពទាំងឡាយជាលក្ខណៈវិស័យ និងអន្តរវិស័យ ដែលជាមគ្គុទ្ទេសក៍សម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ធ្វើជាមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្ររបស់ខ្លួន ដោយតម្រឹមតម្រង់ជាមួយនឹងគោលដៅយុទ្ធសាស្ត្ររួមនៃការអភិវឌ្ឍជាតិ និង[illegible]



ទីស្តីការគណៈរដ្ឋមន្ត្រី លេខ៤១ មហាវិថីសហពន្ធ័រុស្ស៊ី (១១០). រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Website : rgsu.gov.kh / Facebook page : Royal Government Spokesperson Unit / Telegram : https : // t. me / Royal Government Spokesperson

បាវចនាទាំង៥ របស់យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ គឺ កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព និងទី៣. ដើម្បីដាក់ចេញជាយន្តការមួយសម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃ សំដៅធានាការអនុវត្ត ផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ប្រកបដោយជោគជ័យ។ ជារួម សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភានេះ បានដាក់ចេញនូវវិធានការ ផែនការសកម្មភាព កម្មវិធីអាទិភាពតាមវិស័យ និងសូចនាករសមិទ្ធកម្មច្បាស់លាស់សម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីជំរុញឱ្យការអនុវត្តអាចប្រព្រឹត្តទៅរួមគ្នា ប្រទាក់ក្រឡាគ្នា និងបំពេញគ្នាទៅវិញទៅមកប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងសម្រេចបានជោគជ័យ។

បន្ទាប់ពីបានពិភាក្សាយ៉ាងផុលផុសរួចមក អង្គប្រជុំគណៈរដ្ឋមន្ត្រី បានសម្រេចប្រគល់ជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងផែនការ ដើម្បីពិនិត្យនិងកែសម្រួលជាចុងក្រោយ មុននឹងបញ្ជូនទៅរដ្ឋសភា នៅដើមខែឧសភាខាងមុខនេះ។

## ២. សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាស ឆ្នាំ២០២៥-២០៣៥

សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាស ឆ្នាំ២០២៥-២០៣៥ រៀបចំឡើងដើម្បីចូលរួមអនុវត្ត "យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១" របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា ដែលវិស័យអាកាសចរណ៍ស៊ីវិលស្ថិតនៅក្នុងបញ្ចកោណទី២ ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង និងមុំទី២ ការលើកកម្ពស់ការតភ្ជាប់និងការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូន និងឡូជីស្ទីក វិស័យថាមពល វិស័យទឹកស្អាត និងវិស័យឌីជីថល។ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល មានសេចក្តីត្រូវការជាចាំបាច់ដើម្បីដាក់អនុវត្ត "គោលនយោបាយជាតិស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាស ឆ្នាំ២០២៥-២០៣៥" ដែលជាក្របខ័ណ្ឌមួយនៃផែនការយុទ្ធសាស្ត្រអាកាសចរណ៍ស៊ីវិល។ គោលនយោបាយជាតិនេះ ត្រូវបានរៀបចំឡើងដើម្បីអភិវឌ្ឍការដឹកជញ្ជូនតាមផ្លូវអាកាសនៅកម្ពុជាប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងភាពធន់ តាមរយៈគោលនយោបាយពង្រឹងនិងពង្រីកការតភ្ជាប់ជើងហោះហើរតាមផ្លូវអាកាសនៅក្នុងស្រុក តំបន់ និងសកលលោក បង្កើនអត្ថប្រយោជន៍ដល់ការដឹកជញ្ជូនអ្នកដំណើរ និងទំនិញតាមផ្លូវអាកាស និងបង្កើតឱកាសអាជីវកម្មដែលមានការប្រកួតប្រជែងស្មើភាព។

ជាពិសេស គោលនយោបាយជាតិនេះ ផ្តោតសំខាន់លើ ១. នឹងខិតខំអនុវត្តជាបន្តនូវគោលនយោបាយ "បើកចំហជើងមេឃ" ដែលប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី** និងជា**ប្រធានព្រឹទ្ធសភា** ដែលបានដាក់ចេញក្នុងឆ្នាំ១៩៩៨ ហើយបាននិងកំពុងធ្វើឱ្យមានការរីកចម្រើនដល់វិស័យអាកាសចរណ៍ស៊ីវិលកម្ពុជា ព្រមទាំងជួយជំរុញការតភ្ជាប់ទីផ្សារដឹកជញ្ជូនតាមផ្លូវអាកាសក្នុងស្រុកនិងអន្តរជាតិ វិស័យទេសចរណ៍ វិស័យពាណិជ្ជកម្ម និងជួយជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ផងដែរ។ ២. នឹងបន្តជួយគាំទ្រឱ្យកាន់តែរឹងមាំបន្ថែមទៀតដល់លទ្ធផលជាវិជ្ជមាន នៃការដឹកជញ្ជូនតាមផ្លូវអាកាសនៅកម្ពុជាក្នុងឆ្នាំ២០២៤ កន្លងទៅ។ ក្នុងនោះ បានតភ្ជាប់ជើងហោះហើរអន្តរជាតិទៅកាន់ ១២ប្រទេស និងតំបន់រដ្ឋបាលពិសេសហុងកុង និងកោះតៃវ៉ាន់ ឬភ្ជាប់ជើងហោះហើរទៅកាន់រាជធានី/ទីក្រុង ចំនួន ៣៤ ក្នុងតំបន់និងសកលលោក តាមរយៈក្រុមហ៊ុនអាកាសចរណ៍ជាតិ និងអន្តរជាតិសរុបចំនួន ៣១ក្រុមហ៊ុន ដោយមានអ្នកដំណើរតាមផ្លូវអាកាស ចំនួន ៦,២៤លាននាក់ កំណើន ២២% និងទំនិញតាមផ្លូវអាកាស ចំនួន ៧៧,៨៣៩តោន កំណើន ៤០%

ក្នុងការប្រយុទ្ធប្រឆាំង និងបង្ក្រាបការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (ONLINE SCAMS)។ ទោះជាយ៉ាងនេះក្តី បញ្ហានេះនៅតែបន្តកើតមាននៅឡើយ ដែលទាមទារឱ្យមានការចូលរួមបន្ថែមទៀតពីគ្រប់តួអង្គពាក់ព័ន្ធ។

- **សម្តេចធិបតី** បានគូសបញ្ជាក់ថា គណៈកម្មការចំពោះកិច្ចប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា គឺជាយន្តការបំពេញបន្ថែម និងមិនជំនួសយន្តការដែលមានស្រាប់នោះទេ ប៉ុន្តែវាគឺជាសហថាមពលដែលយើងត្រូវបន្តអនុវត្តជាមួយគ្នា ដោយរួមគ្នាទប់ស្កាត់ និងបោសសម្អាតសកម្មភាពខុសច្បាប់ និងអ្នកប្រព្រឹត្តខុសច្បាប់ក្នុងស្មារតីសហការគ្នាជានិច្ច។

- **សម្តេចធិបតី** មានប្រសាសន៍ថា កន្លងទៅនេះ **សម្តេច** បានដាក់ចេញនូវអនុសាសន៍ណែនាំមួយចំនួនពាក់ព័ន្ធនឹងការផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង តាមផ្ទាំងប៉ាណូនៅតាមទីសាធារណៈដោយត្រូវកាត់បន្ថយការផ្សព្វផ្សាយពាណិជ្ជកម្មតាមរយៈផ្ទាំងប៉ាណូធំៗឱ្យមកនៅត្រឹមតែ ៥០% នៃចំនួនផ្ទាំងប៉ាណូផ្សព្វផ្សាយផលិតផលគ្រឿងស្រវឹងសរុបនៅទូទាំងប្រទេស។ ជាមួយគ្នានេះ **សម្តេចធិបតី** បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលរាជធានី-ខេត្ត ដែលមានក្រុមការងារអន្តរក្រសួងគ្រប់គ្រងការផ្សព្វផ្សាយផលិតផលគ្រឿងស្រវឹងដឹកនាំដោយក្រសួងព័ត៌មាន និងដោយអនុវត្តតាមសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ស្តីពីការលើកកម្ពស់ការគ្រប់គ្រងការផ្សព្វផ្សាយពាណិជ្ជកម្មគ្រប់ប្រភេទនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានសម្របសម្រួលនិងដោះស្រាយ ដោយទទួលបានលទ្ធផលល្អប្រសើរ។

- **សម្តេចធិបតី** បានកត់សម្គាល់ថា សហរដ្ឋអាម៉េរិកបាននិងកំពុងខាតបង់ច្រើនលើការចំណាយនាំចូលទំនិញពីបណ្តាប្រទេសលើពិភពលោក ដែលឆ្លុះបញ្ចាំងតាមរយៈឱនភាពជញ្ជីងពាណិជ្ជកម្ម (Trade Deficits) ដូច្នេះហើយ បានជារដ្ឋបាលប្រធានាធិបតី **ឯកឧត្តម ដូណាល់ ត្រាំ** បានប្រកាសដាក់ចេញនូវអត្រាពន្ធនាំចូលឆ្លើយតប (Reciprocal Tariffs) លើបណ្តាប្រទេសដែលសហរដ្ឋអាម៉េរិកមានឱនភាពជញ្ជីងពាណិជ្ជកម្ម។ ជាក់ស្តែង កម្ពុជា ឡាវ និងវៀតណាម ត្រូវទទួលរងនូវអត្រាពន្ធនាំចូលក្នុងកម្រិត ៤៩%, ៤៨%, និង៤៦% រៀងគ្នា ដោយសារសហរដ្ឋអាម៉េរិកមានឱនភាពជញ្ជីងពាណិជ្ជកម្មក្នុងកម្រិត ៩៧% ជាមួយកម្ពុជា ៩៥% ជាមួយឡាវ និង ៩០% ជាមួយវៀតណាម។ ដូច្នេះ ការដាក់អត្រាពន្ធនាំចូលឆ្លើយតបនេះ មិនមែនជាការឆ្លើយតបទៅនឹងអត្រាពន្ធនាំចូលដែលប្រទេសទាំងនោះបានដាក់លើទំនិញនាំចូលពីសហរដ្ឋអាម៉េរិកនោះទេ ហើយការដាក់អត្រាពន្ធនាំចូលឆ្លើយតបនេះទៀតសោត មានតែ ៥០% នៃអត្រាដែលសហរដ្ឋអាម៉េរិកមានឱនភាពជញ្ជីងពាណិជ្ជកម្មជាមួយប្រទេសទាំងនោះតែប៉ុណ្ណោះ។

- **សម្តេចធិបតី** បានបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជានឹងចរចាជាមួយសហរដ្ឋអាម៉េរិកដើម្បីរកដំណោះស្រាយសមស្របណាមួយ។ **សម្តេចធិបតី** បន្តថា បញ្ហានេះអាចបង្កផលប៉ះពាល់មួយចំនួនដោយចៀសមិនរួចមកលើកម្ពុជា ប៉ុន្តែវាមិនអាក្រក់ដូចអ្វីដែលអ្នកលេងបណ្តាញសង្គមមួយចំនួនខំប្រឹងស្រែកបំភ័យនោះឡើយ។ ក្នុងន័យនេះ **សម្តេច** បានអំពាវនាវសូមឱ្យប្រជាពលរដ្ឋ ស្ងប់ចិត្ត ហើយជឿជាក់លើរាជរដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហានេះ។/.

ថ្ងៃសុក្រ ៧កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៥

បើប្រៀបធៀបឆ្នាំ២០២៤ និងឆ្នាំ២០២៣។ ៣. នឹងបន្តជួយគាំទ្រដល់ហេដ្ឋារចនាសម្ព័ន្ធអាកាសចរណ៍ស៊ីវិល ដែលបានសាងសង់រួច ដូចជា អាកាសយានដ្ឋានអន្តរជាតិតេជោ អង្គរ-សៀមរាប និងតារាសាគរ ជាដើម។ គោលនយោបាយជាតិនេះ ក៏មានបំណងសម្រេចឱ្យបាននូវការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាស ចំនួន ២៥ លាននាក់ និងការដឹកជញ្ជូនទំនិញតាមផ្លូវអាកាស ចំនួន ២០៥ពាន់តោន ក្នុងឆ្នាំ២០៣៥ ក្រោមក្របខ័ណ្ឌយុទ្ធសាស្ត្រស្នូលចំនួន ៧ រួមមាន ១. សេរីភាវូបនីយកម្មសិទ្ធិហោះហើរ គោលដៅហោះហើរ និងចំណុះដឹកជញ្ជូន។ ២. សេរីភាវូបនីយកម្មនៃសញ្ជាតិលើម្ចាស់ភាគហ៊ុន និងការគ្រប់គ្រងក្រុមហ៊ុនអាកាសចរណ៍។ ៣. សេរីភាវូបនីយកម្មសេវាកម្មគាំទ្រការដឹកជញ្ជូនតាមផ្លូវអាកាស។ ៤. ការប្រកួតប្រជែងស្មើភាព និងតម្លៃសេវាកម្មប្រកួតប្រជែង។ ៥. ការសម្របសម្រួល និងការប្រើប្រាស់បច្ចេកវិទ្យា។ ៦. សមាហរណកម្មគោលនយោបាយជាតិនេះ ជាមួយនឹងគោលនយោបាយទេសចរណ៍ ពាណិជ្ជកម្ម និងវប្បធម៌ និង៧. ការពង្រឹងគុណភាពសេវាកម្ម និងកិច្ចគាំពារអ្នកដំណើរតាមផ្លូវអាកាស។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលសង្ឃឹមយ៉ាងមុតមាំថា តាមរយៈគោលនយោបាយជាតិនេះ វិស័យដឹកជញ្ជូនតាមផ្លូវអាកាសនៅកម្ពុជា នឹងមានការរីកចម្រើនយ៉ាងខ្លាំង ដោយជំរុញការតភ្ជាប់ទីផ្សារអាកាសចរណ៍ក្នុងស្រុកនិងអន្តរជាតិ និងធានាបាននូវចីរភាពនៃការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចកម្ពុជា។

## ៣. បញ្ហាផ្សេងៗ៖

- **សម្តេចធិបតី** បានណែនាំឱ្យគណៈបញ្ជាការរាជធានី-ខេត្ត អាជ្ញាធរពាក់ព័ន្ធ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ត្រូវពង្រឹងការងារសន្តិសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរនឹងចូលមកដល់នៅក្នុងរយៈពេលប៉ុន្មានថ្ងៃខាងមុខនេះ ដោយឆ្នាំនេះយើងនឹងរៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្តទូទាំងប្រទេសឱ្យមានលក្ខណៈអធិកអធម ដើម្បីអបអរពិធីបុណ្យចូលឆ្នាំថ្មីផង និងដើម្បីទាក់ទាញភ្ញៀវទេសចរផង។ ទន្ទឹមនេះ ត្រូវពង្រឹងការគ្រប់គ្រងសភាពការណ៍នៅតាមមូលដ្ឋាន ដើម្បីត្រៀមខ្លួនដាក់ចេញនូវចំណាត់ការទប់ស្កាត់ឱ្យបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព នូវរាល់សកម្មភាពប៉ុនប៉ងបង្កឱ្យមានចលាចល វឹកវរ និងអសន្តិសុខក្នុងសង្គម និងត្រូវយកចិត្តទុកដាក់ចំពោះការការពារសន្តិសុខ និងសុវត្ថិភាពជូនថ្នាក់ដឹកនាំ ភ្ញៀវជាតិ-អន្តរជាតិ និងបងប្អូនប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានប្រកបដោយស្មារតីប្រុងប្រយ័ត្នខ្ពស់។

- **សម្តេចធិបតី** បានណែនាំឱ្យរដ្ឋបាលរាជធានី-ខេត្ត ត្រូវសហការជាមួយក្រុមហ៊ុនឯកជន និងអាជីវករក្នុងការរក្សាតម្លៃម្ហូបអាហារ ភេសជ្ជៈ និងសេវាឱ្យបានសមរម្យ ក្នុងអំឡុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ។

- **សម្តេចធិបតី** បានរម្លឹកអំពីការឧបត្ថម្ភថវិកា ៥ម៉ឺនរៀល ជូនដល់មន្ត្រីរាជការសម្រាប់ពិធីបុណ្យចូលឆ្នាំថ្មី និងការរៀបចំរថយន្តក្រុងសាធារណៈជូនប្រជាពលរដ្ឋធ្វើដំណើរពីរាជធានីទៅតាមបណ្តាខេត្ត និងការវិលត្រឡប់មកវិញ ដោយឥតគិតថ្លៃ រយៈពេល៦ថ្ងៃ ចាប់ពីថ្ងៃទី១២ ដល់ ទី១៧ ខែមេសា ឆ្នាំ២០២៥។ តាមរយៈកម្មវិធីនេះ រាជរដ្ឋាភិបាលបានជួយសម្រាលបន្ទុកការចំណាយ ក្នុងការធ្វើដំណើររាប់លានដុល្លារជូនប្រជាពលរដ្ឋ។

- **សម្តេចធិបតី** បានវាយតម្លៃខ្ពស់ចំពោះគ្រប់ក្រសួង-ស្ថាប័ន និងកងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធ ជាពិសេសក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី-ខេត្ត ដែលបានខិតខំបំពេញការងារយ៉ាងសស្រាក់សស្រាំ ប្រកបដោយលទ្ធផលជាផ្លែផ្កា